USAID FROM THE AMERICAN PEOPLE

Health Systems Strengthening in Cambodia URC


# សម្លេង USAID HSSC

គំរោងពង្រឹងប្រព័ន្ធសុខាភិបាលកម្ពុជារបស់ទីភ្នាក់ងារដើម្បីការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក អនុវត្តដោយអង្គការ URC

លេខ៧ ខែឧសភា ឆ្នាំ២០០៧


## ការពង្រឹងប្រព័ន្ធសុខាភិបាលតាមរយៈការលើកកំពស់គុណភាព

ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាលឆ្នាំ២០០៣-២០០៧, បានកំណត់យកការកែលំអគុណភាពសេវាជាអាទិភាពមួយសំរាប់ប្រព័ន្ធសុខាភិបាលកម្ពុជា។ អង្គការ USAID-HSSC/URC និងដៃគូសុខាភិបាល ដូចជាការិយាល័យធានាគុណភាព ក្រុមការងារកែលំអគុណភាព បានរួមគ្នាអភិវឌ្ឍន៍ឧបករណ៍វាយតំលៃមន្ទីរពេទ្យ ដើម្បីអនុវត្តគំរោងកែលំអគុណភាពនៅក្នុងមន្ទីរពេទ្យទាំងប្រាំបី ដែលគាំទ្រដោយអង្គការ USAID-HSSC/URC។ ដៃគូដ៏ទៃទៀត ដូចជាអង្គការ GTZ, BTC ក៏បានសហការជាមួយក្រសួងសុខាភិបាលប្រើប្រាស់ឧបករណ៍នេះនៅមន្ទីរពេទ្យមួយចំនួនបន្ថែមទៀត។



គំរោងកែលំអគុណភាពនេះផ្អែកទៅលើគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និងទាក់ទងនឹងការវាយតំលៃជាផ្លូវការ ដើម្បីត្រួតពិនិត្យការរីកចំរើនរួមជាមួយនឹងកិច្ចប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីកែលំអគុណភាព។ នៅក្នុងរូបភាពនេះ បុគ្គលិកនៅមន្ទីរពេទ្យបង្អែកឆ្លូង ខេត្តក្រចេះ ទទួលការបណ្តុះបណ្តាលដើម្បីកែលំអគុណភាពនៃការប្រើប្រាស់ឱសថ។

លោកវេជ្ជ. ឡៀក ហួរម៉ាន់ ប្រធានគំរោង BTC បញ្ជាក់ថា ឧបករណ៍វាយតំលៃដែលផ្តួចផ្តើមអភិវឌ្ឍដោយ USAID-HSSC/URC “មានប្រយោជន៏ណាស់” ដោយមានផលប្រយោជន៏ធំៗដូចតទៅនេះ :

- គំរោងនេះបានប្រើប្រាស់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និងខ្សែទទឹងជាជាងវិធីសាស្ត្រ ផ្អែកតាមខ្សែបណ្តោយ។
- ឧបករណ៏ត្រូវបានរចនាឡើងសំរាប់ការវាយតំលៃដែលមានចន្លោះពេលជាញឹកញាប់ ដែលអាចអនុញ្ញាតអោយយើងតាមដានជាទៀងទាត់ នូវការវិវត្តន៏របស់គំរោង។
- ដោយសារគំរោងបានអភិវឌ្ឍនៅក្នុងប្រព័ន្ធសុខាភិបាល ឧបករណ៏នេះអាចសំរបតំរូវយ៉ាងងាយស្រួលទៅតាមស្ថានការផ្លាស់ប្តូរ។

### គោលបំណងនៃគំរោងកែលំអគុណភាពតាមរយៈការវាយតំលៃមន្ទីរពេទ្យ

១. ពង្រឹងប្រព័ន្ធសំរាប់តាមដានគុណភាពសេវា និងលទ្ធផលមន្ទីរពេទ្យ ដោយផ្អែកទៅលើគោលការណ៏ណែនាំស្តីអំពីសំណុំសកម្មភាពបង្គ្រប់របស់ក្រសួងសុខាភិបាល។

២. ពង្រឹងសមត្ថភាពក្រុមអ្នកគ្រប់គ្រង ដើម្បីប្រើប្រាស់ធនធានអោយមានប្រសិទ្ធភាពក្នុងការផ្តល់សេវា ដែលប្រកបដោយគុណភាព។

៣. តស៊ូមតិដើម្បីការកែលំអដោយលើកយកបញ្ហាសំខាន់ៗដែលមានលក្ខណៈជាប្រព័ន្ធពីមន្ទីរពេទ្យ មកទាក់ទាញអារម្មណ៏នៅក្រសួងសុខាភិបាលថ្នាក់ជាតិ។